អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨

# សេចក្តីប្រកាសព័ត៌មាន

## នួន ជា និង ខៀវ សំផន ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត នៅក្នុងសំណុំរឿង ០០២/០២

នៅថ្ងៃនេះ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) បានសម្រេចផ្តន្ទាទោសអតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម **នួន ជា** និង **ខៀវ សំផន** ពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩។ ឧក្រិដ្ឋកម្មទាំងនេះត្រូវបានប្រព្រឹត្តនៅតាមទីកន្លែងនានានៅទូទាំងប្រទេសកម្ពុជា ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។

អង្គជំនុំជម្រះសាលាដំបូងបានប្រកាសសេចក្តីសង្ខេបផ្នែកសំអាងហេតុ និងផ្នែកសេចក្តីសម្រេចរបស់ខ្លួន នៅក្នុងសំណុំរឿង ០០២/០២ នៅក្នុងសវនាការជាសាធារណៈដែលបានធ្វើឡើងនៅថ្ងៃនេះ ***ថ្ងៃសុក្រ ទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨*** ដោយសម្រេចផ្តន្ទាទោសជនជាប់ចោទ នួន ជា និង ខៀវ សំផន ដាក់**ពន្ធនាគារអស់មួយជីវិត**។ អង្គជំនុំជម្រះនឹងចេញសំអាងហេតុពេញលេញជាលាយលក្ខណ៍អក្សរសម្រាប់សាលក្រមរបស់ខ្លួន នៅក្នុងពេលសមស្របខាងមុខ។

សវនាការពិនិត្យភ័ស្តុតាងក្នុងសំណុំរឿង ០០២/០២ បានចាប់ផ្តើមដោយការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ និងបានបញ្ចប់នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧។ ការជំនុំជម្រះ រួមទាំងការស្តាប់សេចក្តីសន្និដ្ឋានផ្ទាល់មាត់បិទបញ្ចប់កិច្ចពិភាក្សាដេញដោលផង មានរយៈពេលសរុបចំនួន ២៨៣ថ្ងៃ។ ក្នុងអំឡុងពេលសវនាការនេះ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សក្ខីកម្មបុគ្គលសរុបចំនួន ១៨៥នាក់ ក្នុងនោះមានសាក្សីចំនួន ១១៤នាក់ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៦៣នាក់ និងអ្នកជំនាញចំនួន ៨នាក់។ ការជំនុំជម្រះនេះទទួលបាននូវការចាប់អារម្មណ៍យ៉ាងខ្លាំងពីសាធារណជន ដោយមានសាធារណជនចូលរួមស្តាប់ និងតាមដាននូវដំណើរការសវនាការនេះ

ដោយផ្ទាល់សរុបចំនួន ៨២.៧៨០នាក់។

**សំអាងហេតុសំខាន់ៗរបស់អង្គជំនុំជម្រះ**

អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា នួន ជា ដែលជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា (ប.ក.ក.) និង ខៀវ សំផន ដែលជាប្រមុខរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យបានចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម ជាមួយមេដឹកនាំជាន់ខ្ពស់ដទៃទៀតនៃបក្សកុម្មុយនីស្តកម្ពុជា ដោយមានគោលបំណងអនុវត្តបដិវត្តន៍សង្គមនិយមឆាប់រហ័ស តាមរយៈការប្រព្រឹត្តឧក្រិដ្ឋកម្មនានា។

នួន ជា និង ខៀវ សំផន ត្រូវបានផ្តន្ទាទោសពីការប្រព្រឹត្ត តាមរយៈការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួមនូវៈ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទៅលើក្រុមជាតិ ជាតិពន្ធុ និងពូជសាសន៍វៀតណាម ការបំពារបំពានយ៉ាងធ្ងន់ធ្ងរជាច្រើនទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ ព្រមទាំងអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការជម្លៀសដោយបង្ខំ អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទនៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ ជនជាប់ចោទទាំងពីររូបក៏ត្រូវបានផ្តន្ទាទោសផងដែរពីការជួយ និងជំរុញឱ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមរយៈការធ្វើមនុស្សឃាត នៅតាមការដ្ឋានការងារ សហករណ៍ និងមន្ទីរសន្តិសុខ ចំពោះការស្លាប់ដែលបណ្តាលមកពីលក្ខខណ្ឌនៃការរស់នៅ នៅតាមទីតាំងឧក្រិដ្ឋកម្មទាំងនេះ រួមមាន កង្វះម្ហូបអាហារ ទឹក និងការថែទាំសុខភាព ព្រមទាំងការកំណត់ឱ្យធ្វើការងារធ្ងន់ធ្ងរ។

ដោយឡែក នួន ជា ត្រូវបានផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ តាមរយៈការធ្វើមនុស្សឃាតទៅលើសមាជិកនៃក្រុមជាតិពន្ធុចាម និងសាសនា ដោយផ្អែកលើការទទួលខុសត្រូវក្នុងនាមជាថ្នាក់លើរបស់គាត់។

ឧក្រិដ្ឋកម្មនានាដែលត្រូវបានប្រព្រឹត្តនៅតាមទីតាំងឧក្រិដ្ឋកម្មនានានៅទូទាំងប្រទេស រួមមាន នៅសហករណ៍ត្រាំកក់ ការដ្ឋានការងារទំនប់ត្រពាំងថ្ម ការដ្ឋានការងារទំនប់ ១ មករា ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង មន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង និងមន្ទីរសន្តិសុខភ្នំក្រោល។

អង្គជំនុំជម្រះបានរកឃើញថា នួន ជា បានដើរតួនាទីជា “ដៃស្តាំ” របស់ ប៉ុល ពត ដោយបានចូលរួមនៅក្នុងការចេញសេចក្តីសម្រេចសំខាន់ៗទាំងអស់របស់បក្សកុម្មុយនីស្តកម្ពុជា។ គាត់បានដើរតួនាទីក្នុងការរៀបចំ អនុវត្ត និងផ្សព្វផ្សាយនូវគោលនយោបាយ និងការឃោសនារបស់បក្សកុម្មុយនីស្តកម្ពុជា ឧទាហរណ៍ គាត់ជានិពន្ធនាយកនៃ

ទស្សនាវដ្ដីឃោសនារបស់របបខ្មែរក្រហមឈ្មោះ *ទង់បដិវត្ត* និងបានចូលរួមចំណែកយ៉ាងធំធេងនៅក្នុងឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តដោយកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា។ អង្គជំនុំជម្រះក៏បានរកឃើញផងដែរថា នួន ជា បានចូលរួមនៅក្នុងការបោសសម្អាតខ្មាំង និងដំណើរការរបស់មន្ទីរសន្តិសុខ ស-២១។

អង្គជំនុំជម្រះបានរកឃើញថា ខៀវ សំផន បានជំរុញ ញុះញង់ និងផ្តល់ភាពស្របច្បាប់ដល់គោលនយោបាយឧក្រិដ្ឋនានា ហើយបានចូលរួមចំណែកយ៉ាងធំធេងនៅក្នុងឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តដោយកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា។ គាត់បានណែនាំដោយផ្ទាល់ដល់កម្មាភិបាល ស្តីពីការអនុវត្តគោលនយោបាយឧក្រិដ្ឋ និងទទួលខុសត្រូវក្នុងការបណ្តុះបណ្តាលកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា។ លើសពីនេះទៅទៀត អង្គជំនុំជម្រះបានរកឃើញថា ខៀវ សំផន បានចូលរួមចំណែកនៅក្នុងការបោសសម្អាតខ្មាំងនៅទូទាំងប្រទេស និងបានអនុម័តផ្តល់ "សិទ្ធិក្នុងការកម្ទេច" នៅក្នុងជួរថ្នាក់ក្រោមនៃបក្សកុម្មុយនីស្តកម្ពុជា។ ខៀវ សំផន ក៏ទទួលខុសត្រូវផងដែរក្នុងការថ្លែងសុន្ទរកថាគាំទ្រដល់គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាដែលត្រូវបានផ្សព្វផ្សាយជាសាធារណៈ ដែលអង្គជំនុំជម្រះបានរកឃើញថា ជាការចូលរួមចំណែកនៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម។

## ឧក្រិដ្ឋកម្មនានាដែលត្រូវបានប្រព្រឹត្ត៖ គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា

អង្គជំនុំជម្រះបានរកឃើញថា បក្សកុម្មុយនីស្តកម្ពុជាបានបង្កើតឲ្យមានសហករណ៍ និងការដ្ឋានការងារដោយបង្ខំឲ្យប្រជាជនធ្វើការនៅក្នុងស្ថានភាពយ៉ាងអមនុស្សធម៌ ដោយមិនមានអាហារគ្រប់គ្រាន់ គ្មានទឹកស្អាត ឬគ្មានការថែទាំសុខភាពគ្រប់គ្រាន់ឡើយ។ ប្រជាជនកម្ពុជារាប់ម៉ឺននាក់ត្រូវបានធ្វើឲ្យទៅជាទាសករ ហើយប្រជាជនមួយចំនួនធំបានស្លាប់ដោយសារការដាក់ឲ្យស្ថិតនៅក្នុងស្ថានភាពទាំងនេះ។ អង្គជំនុំជម្រះបានរកឃើញបន្ថែមថា បក្សកុម្មុយនីស្តកម្ពុជាបានបង្កើតឲ្យមានមន្ទីរសន្តិសុខ ដើម្បីកំណត់អត្តសញ្ញាណ ក្នុងការចាប់ខ្លួន ដាក់ឲ្យនៅដាច់ដោយឡែក និងសម្លាប់បុគ្គលទាំងឡាយណាដែលរបបនោះចាត់ទុកថាជាខ្មាំង។ ប្រពន្ធ និងកូនៗរបស់អ្នកដែលគេចាត់ទុកថាជាខ្មាំងទាំងនោះ ក៏ត្រូវបានសម្លាប់ដូចគ្នាដែរ។

អង្គជំនុំជម្រះសាលាដំបូងក៏បានរកឃើញផងដែរថា នួន ជា និង ខៀវ សំផន ទទួលខុសត្រូវចំពោះគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ដែលកំណត់គោលដៅប្រឆាំងនឹងជនជាតិវៀតណាម ជនជាតិចាម ពុទ្ធសាសនិក និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងក្រុមគ្រួសាររបស់ពួកគេ។ អង្គជំនុំជម្រះបានរកឃើញថា នៅចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៦ មានគោលនយោបាយនៅទូទាំងប្រទេសក្នុងការបណ្តេញប្រជាជនវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជា។ អង្គជំនុំជម្រះបានបង្ហាញផងដែរនូវករណីជាក់លាក់ដែលប្រជាជនស៊ីវិលវៀតណាមត្រូវបានសម្លាប់ជាទ្រង់ទ្រាយធំ។ ប្រជាជនស៊ីវិលនិងទាហានវៀតណាមរាប់រយនាក់ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខ ស-២១ ក្រោយពេលទទួលរងការធ្វើទារុណកម្ម និងស្ថិតនៅក្នុងស្ថានភាពយ៉ាងអមនុស្សធម៌។ និមិត្តរូបនៃព្រះពុទ្ធសាសនាត្រូវបានកម្ទេចចោល ហើយព្រះសង្ឃត្រូវបានចាប់ផ្សឹកដោយបង្ខំនៅតាមឃុំនានា។ ព្រះសង្ឃត្រូវបានគេចាត់ទុកថាជា

“តេនញ៉ា” ឬ “ឈ្លើង” សង្គម ហើយការប្រើប្រាស់វត្តអារាមក្នុងគោលបំណងខាងសាសនាមិនត្រូវបានអនុញ្ញាតឡើយ។ ការប្រតិបត្តិសាសនា និងវប្បធម៌ចាម ត្រូវបានហាមឃាត់នៅទូទាំងប្រទេសកម្ពុជា។ ព្រះវិហារអ៊ីស្លាមត្រូវបានរុះរើ និងគម្ពីរអាល់គូរ៉ាអានត្រូវបានដុតចោល។ ប្រជាជនចាមត្រូវបានបង្ខំឱ្យបរិភោគសាច់ជ្រូក និងត្រូវបានហាមមិនឱ្យគោរពបូជាសាសនា និងនិយាយភាសាដើមរបស់ខ្លួនឡើយ។ លើសពីនេះទៅទៀត អង្គជំនុំជម្រះបានរកឃើញថា ប្រជាជនស៊ីវិលចាមត្រូវបានចាប់ខ្លួន និងសម្លាប់ក្នុងទ្រង់ទ្រាយធំនៅមន្ទីរសន្តិសុខវត្តអូរត្រកួន និងមន្ទីរសន្តិសុខភូមិទ្រា។ អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរក៏ត្រូវបានកំណត់គោលដៅ ដើម្បីចាប់ខ្លួន និងសម្លាប់ជាមួយក្រុមគ្រួសាររបស់ពួកគេផងដែរ។

ជាចុងក្រោយ អង្គជំនុំជម្រះបានរកឃើញថា នួន ជា និង ខៀវ សំផន ទទួលខុសត្រូវចំពោះគោលនយោបាយនៅទូទាំងប្រទេសនៃការកំណត់អត្តសញ្ញាណបុគ្គលដែលត្រូវរៀបការដោយបង្ខំ ដែលជាញឹកញាប់គឺត្រូវរៀបការជាមួយមនុស្សដែលពួកគេមិនធ្លាប់ស្គាល់។ ក្រោយពេលរៀបការជាក្រុមនេះ ប្តីប្រពន្ធត្រូវបានតាមដានដោយពួកកងឈ្លប ហើយត្រូវបានបង្ខំឱ្យរួមភេទជាមួយប្តី/ប្រពន្ធដែលទើបរៀបការថ្មីថ្មោងរបស់ពួកគេ។ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាដើរតួនាទីជាឪពុកម្តាយ ក្នុងការជ្រើសរើសគូស្រករដែលសក្តិសម បង្ខំពួកគេឱ្យរៀបការជាមួយគ្នា និងបង្កើតកូនក្នុងគោលបំណងបង្កើនចំនួនប្រជាជននៅក្នុងប្រទេស។

***

អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣.៨៦៥នាក់ និងជនរងគ្រោះជាច្រើននាក់ទៀត បានទទួលរងព្យសនកម្មជាច្រើនឥតគណនា ដោយសារតែឧក្រិដ្ឋកម្មដែល នួន ជា និង ខៀវ សំផន ត្រូវបាន ផ្តន្ទាទោស។ ហេតុដូច្នេះ អង្គជំនុំជម្រះគាំទ្រដល់ការអនុវត្តគម្រោងសំណងចំនួន ១៣ ដែលទទួលស្គាល់នូវព្យសនកម្ម ដែលដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះផ្សេងៗទៀតបានទទួលរង។

នៅក្នុងការជំនុំជម្រះលើកទីមួយពាក់ព័ន្ធនឹងជនជាប់ចោទទាំងពីរនាក់នេះ គឺសំណុំរឿង ០០២/០១ នួន ជា និង ខៀវ សំផន ត្រូវបានផ្តន្ទាទោសដោយអង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ ហើយបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតចំពោះឧក្រិដ្ឋកម្មទាំងនោះ។ ការផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតនៅក្នុងសំណុំរឿង ០០២/០១ ត្រូវបានតម្កល់បន្ទាប់ពីមានបណ្តឹងសាទុក្ខ។ អង្គជំនុំជម្រះសាលាដំបូងរួមបញ្ចូលគ្នានូវការផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតនៅក្នុងសំណុំរឿង ០០២/០១ និង សំណុំរឿង ០០២/០២ ទៅជាការផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត តែមួយ សម្រាប់ជនជាប់ចោទម្នាក់ៗ។ នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧ អង្គជំនុំជម្រះសាលាដំបូងបានបញ្ចប់កិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងអង្គហេតុទាំងអស់ដែលបានកំណត់នៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿង ០០២ ដែលមិនត្រូវបានបញ្ចូលនៅក្នុងសំណុំរឿង ០០២/០១ ឬសំណុំរឿង ០០២/០២។

សេចក្តីសង្ខេបនៃសាលក្រមដែលបានប្រកាសដោយអង្គជំនុំជម្រះសាលាដំបូង នឹងមានផ្សាយនៅក្នុងគេហទំព័ររបស់ អ.វ.ត.ក.

***សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖***


លោក នេត្រ ភក្ត្រា

ប្រធានផ្នែកកិច្ចការសាធារណ: និងជាមន្ត្រីនាំពាក្យ

ទូរស័ព្ទចល័ត +៨៥៥(០)១២ ៤៨៨ ១៥៦/០១២ ៤៨៣ ២៨៣

អ៊ីមែល៖ neth.pheaktra@eccc.gov.kh